# របាយការណ៍នៃកិច្ចប្រជុំពិភាក្សា
# ចងក្រងឯកសារយុវវ័យងាយរងគ្រោះដោយសារជំងឺអេដស៍នៅកម្ពុជា

# 3

នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០១៤ វេលាម៉ោង ៨ : ៣០ នាទី ព្រឹក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំមួយ ស្តីពីការចងក្រងឯកសារយុវវ័យងាយរងគ្រោះ ដោយសារជំងឺអេដស៍ នៅកម្ពុជា ។ កិច្ចប្រជុំនេះ បានដឹកនាំ**ដោយ ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

**គោលបំណងនៃកិច្ចប្រជុំ**

- ពិនិត្យ និង ភាក្សាលើគោលនយោបាយថ្មី របស់រាជរដ្ឋាភិបាលកម្ពុជា ដែលទាក់ទងនឹងយុវវ័យ
- រៀបចំចងក្រងឯកសារគោល ស្តីពីយុវវ័យងាយរងគ្រោះ ដោយសារមេរោគអេដស៍ និង គ្រឿងញៀននៅកម្ពុជា ។

**សមាសភាពចូលរួមមានៈ**

កិច្ចប្រជុំនេះ ត្រូវបានដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានសមាជិកចូលរួមពីស្ថាប័ន និង អង្គការដៃគូនានា ដូចជា ក្រសួងអប់រំ យុវជន និង កីឡា អង្គការ UNESCO, UNFPA, KHANA, FHI360, National MSM Network, EW Network, KORSANG, PHD, MHSS, One World, CCHR, CSSD, CCW, CCECM, CWPD និង Youth LEAD ។

**របៀបវារៈនៃកិច្ចប្រជុំ**

- បង្ហាញពីគោលនយោបាយថ្មី របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និង មេរោគអេដស៍ ។
- ការបង្ហាញដោយសង្ខេបពីបញ្ញាគម្រោងកំពុងអនុវត្ត និង បានអនុវត្ត ដែលទាក់ទងនឹងយុវវ័យ
- ការពិភាក្សា ដើម្បីប្រមូលពត៌មាន និង ចងក្រងឯកសារនៃយុវវ័យងាយរងគ្រោះ ដោយសារមេរោគអេដ៍ និង គ្រឿងញៀននៅកម្ពុជា ។

**ដំណើរការ និង លទ្ធផលនៃកិច្ចពិភាក្សា**

បន្ទាប់ពីអ្នកចូលរួមទាំងអស់ បានជួបជុំគ្នា ឯកឧត្តមវេជ្ជ. តែខ ឥន្ទី អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ជាប្រធានអង្គប្រជុំ បានស្វាគមន៍ ដោយបង្ហាញពីគោលបំណងចាប់ផ្តើមកិច្ចពិភាក្សា ។

ឯកឧត្តមប្រធានអង្គប្រជុំ បានបង្ហាញពីស្ថានភាពទូទៅរបស់យុវវ័យនៅកម្ពុជា ដោយផ្អែកតាមរយៈការសិក្សារបស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីយុវវ័យប្រឈមមុខខ្ពស់ ដោយសារជំងឺអេដស៍ នៅឆ្នាំ ២០១០ និង ការសិក្សាពីបទពិសោធន៍ និង ឥរិយាបទងាយប្រឈមរបស់យុវវ័យ ដែលធ្វើការកន្លែងកម្សាន្តសប្បាយ ។

តាមរយៈការសិក្សាបានបង្ហាញថា

- មានយុវវ័យជាស្ត្រីប្រមាណជា ៧០% និង បុរសប្រមាណជា ៩១% បានសេពគ្រឿងស្រវឹង
- យុវវ័យជាស្ត្រី ៣.៥% និង បុរសប្រមាណជា ១៥.២% ប្រើប្រាស់គ្រឿងញៀន
- ប្រមាណលើសពី ៤១% នៃយុវជន និង ២៣% នៃយុវតីបានរៀបរាប់ថា ពួកគេមានភាពសកម្មក្នុងការរួមភេទ ។

ហេតុផល និង ពត៌មានទាំងអស់នេះ បានបង្ហាញថា ប្រទេសកម្ពុជាយើង មានយុវវ័យជាច្រើនកំពុងតែប្រឈមមុខនឹងបញ្ហាការឆ្លងរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ និង ផលប៉ះពាល់ដោយសារគ្រឿងញៀន ។ ដូចនេះហើយ បានជារាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយថ្មី ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍នៅកម្ពុជា ។ គោលការណ៍ថ្មីនេះ មាន ៧ចំណុចសំខាន់រួមមានៈ

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការណ៍ជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ដើម្បីជំរុញ និង លើកទឹកចិត្ត ឱ្យមានការប្រើប្រាស់ស្រោមអនាម័យ ១០០% ដើម្បីសុវត្ថិភាពក្នុងការរួមភេទ ឱ្យរួចចាកឆ្ងាយពីមេរោគអេដស៍ និង ជំងឺអេដស៍ ។

២. បញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ និង សុខភាពមាតា ជាចំណុចបន្ថែម នៃគោលនយោបាយភូមិឃុំ មានសុវត្ថិភាព ។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និង ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល ត្រូវសហការគ្នារៀបចំផែនទីបញ្ជាក់ពីភូមិសាស្ត្រ ចំនួនអ្នករស់នៅជាមួយមេរោគអេដស៍ និង ក្រុមងាយរងគ្រោះ ដែលរួមមាននារីបម្រើសេវាកំសាន្ត បុរសស្រឡាញ់បុរស កុមារកំព្រា ដែលឪពុកម្តាយស្លាប់ ដោយសារជំងឺអេដស៍ ជនចំណាកស្រុក ដែលរស់នៅជាមួយមេរោគអេដស៍ ចំនួន និង ទីកន្លែង មន្ទីរផ្តល់សេវាព្យាបាលជំងឺអេដស៍ ។

៤. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចាត់វិធានការណ៍ ធ្វើឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំរាជធានី-ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មានសកម្មភាពឡើងវិញ ។ គណៈកម្មា ធិការអេដស៍ខេត្ត

នីមួយៗ ត្រូវពង្រឹងលក្ខណៈជាដៃគូ ជាមួយអង្គការសង្គមស៊ីវិល ដែលកំពុងដំណើការ នៅក្នុងខេត្តរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៥. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និង បណ្តាក្រសួងពាក់ព័ន្ធ ត្រូវសហការណ៍គ្នា ដើម្បីអនុញ្ញាតឱ្យជនងាយរងគ្រោះ ដោយជំងឺអេដស៍ ដែលជាអាទិ៍ ៖ នារីបម្រើសេវាកំសាន្ត បុរសស្រឡាញ់បុរស អ្នកញៀនគ្រឿងញៀនប្រើម្ជុល អាចទទួលបានសេវាព្យាបាលជំងឺអេដស៍ បានយ៉ាងទូលំទូលាយ។

៦. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការណ៍ជាមួយក្រសួងអប់រំ យុវជន និង កីឡា អង្គការយុវជន ស្ថាប័នពាក់ព័ន្ធ **ដើម្បីបង្កើនការអប់រំដល់យុវជន យុវនារី ឱ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និង វិធីបង្ការ ការពារឱ្យបានទូលំទូលាយ ។**

៧. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំ សម្របសម្រួល និង តាមដានការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ ដូចមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ស្របតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការនិតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ដោយយោងទៅលើគោលនយោបាយថ្មីនេះ ជាពិសេសនៅត្រង់ចំណុចទី៦ ដែលជាការចង្អុលបង្ហាញដ៏សំខាន់មួយទាំងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាត្រូវទទួលខុសត្រូវ ក្នុងការសម្រេចឱ្យបាននូវគោលនយោបាយនេះ ឱ្យបានមុនឆ្នាំ ២០២០។

តាមរយៈការបង្ហាញដោយសង្ខេបរបស់អ្នកចូលរួម ដែលមកពីក្រសួងអប់រំ យុវជន និង កីឡា អង្គការ UNFPA, UNESCO, KHANA, CCHR, CSSD, EW Network និង តំណាងបណ្តាញយុវជនងាយរងគ្រោះដោយសារជំងឺអេដស៍ បានបង្ហាពីកម្មវិធី និង សកម្មភាព ដែលកំពុងតែអនុវត្តដូចខាងក្រោម ៖

- ក្នុងពេលបច្ចុប្បន្ននេះ មិនទាន់មានអង្គការ ឬ កម្មវិធីណាមួយដែលអនុវត្ត ឬ ធ្វើការងារផ្ទាល់ជាមួយយុវវ័យងាយរងគ្រោះ ដោយសារជំងឺអេដស៍នៅឡើយទេ ។ កម្មវិធីភាគច្រើន គឺផ្តោតលើសុខភាពបន្តពូជ យែនឌ័រ ប្រជាធិបតេយ្យ សិទ្ធិ និង ការផ្តល់សិទ្ធិអំណាចដល់យុវវ័យក្នុងការចូលរួមសេចក្តីសម្រេចចិត្ត ឬ កិច្ចការនានា ។
- ក្រសួងអប់រំ យុវជន និង កីឡា បានកំពុងតែអនុវត្ត នូវកម្មវិធីការអប់រំសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ សម្រាប់ការអប់រំក្នុងវិស័យអប់រំ ចាប់ពីថ្នាក់បឋមសិក្សា រហូតដល់សាកលវិទ្យាល័យ ក្នុងនោះអង្គការ PHD ក៏បានចូលរួមអនុវត្តកម្មវិធីនេះ នៅតាមសាកលវិទ្យាល័យចំនួន ២៩ ។ ក្រសួងអប់រំ ក៏កំពុងតែបានអនុវត្តកម្មវិធីនេះ ចំពោះយុវវ័យក្រៅសាលាផងដែរ តាមរយៈការអប់រំចល័តនៅសហគមន៍ ។

- អង្គការ ខាណា (KHANA) ដែលជាអង្គការធំមួយនៅកម្ពុជា ដែលកំពុងធ្វើការជាមួយអង្គការដៃគូប្រមាណជា ៣៨ អង្គការ ក្នុង ២០ រាជធានី-ខេត្ត លើបទអន្តរាគមន៍បង្ការ ថៃទាំ និង គាំទ្រដល់ក្រុមងាយរងគ្រោះ ដោយសារមេរោគអេដស៍ និង ជំងឺអេដស៍ (MSM, TG, EWs, PWUD/PWID)។ បើយោងលើនិយមន័យរបស់ថ្នាក់ជាតិ ជាពិសេសក្រសួងអប់រំ យុវជន និង កីឡា ដែលបានកំណត់អាយុ ពី១៥ ទៅដល់ ៣០ ឆ្នាំ សម្រាប់យុវវ័យនោះ គឺភាគច្រើននៃក្រុមគោលដៅ ដែលត្រូវបានគ្របដណ្តប់សុទ្ធតែជាយុវវ័យ ។ ដូចនេះ បើយើងមានបទអន្តរាគមន៍ច្បាស់លាស់សម្រាប់ពួកគេ គឺជាការសំខាន់ និង ចាំបាច់បំផុត ដែលធ្វើការឆ្លើយតបទៅនឹងមេរោគអេដស៍មានប្រសិទ្ធភាព ។
- នៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីភិច មានបណ្តាញយុវវ័យងាយរងគ្រោះ ដោយសារមេរោគអេដស៍ និង ជំងឺអេដស៍ ដែលមានឈ្មោះថា Youth LEAD ដែលជាបណ្តាញយុវវ័យតែមួយគត់ ដែលធ្វើការងារ ជាតំណាងរបស់យុវវ័យងាយរងគ្រោះនៅថ្នាក់តំបន់ ។ ប្រទេសកម្ពុជា ក៏មានជនបង្គោល (Focal Point) ធ្វើការងារសម្រាប់បណ្តាញនេះដែរ ហើយជាយុវវ័យមកពីសហគមន៍ក្រុមងាយរងគ្រោះផ្ទាល់ ។ ការងារគោលរបស់ Youth LEAD គឺដើរតួនាទីជាអ្នកតំណាងយុវវ័យងាយរងគ្រោះ ដោយសារជំងឺអេដស៍នៅវេទិកាថ្នាក់ជាតិ និង ថ្នាក់តំបន់ ធ្វើការងារសម្របសម្រួលការអភិវឌ្ឍ ការគាំទ្រ និង ការកសាងសមត្ថភាពសម្រាប់យុវវ័យងាយរងគ្រោះ ដើម្បីឱ្យពួកគេក្លាយជាអ្នកដឹកនាំជំនាន់ថ្មី ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ ។

តាមរយៈការពិភាក្សា អ្នកចូលរួមទាំងអស់ បានឯកភាពគ្នា លើចំណុចសំខាន់ ដូចខាងក្រោម ៖

- ឯកសារដែលត្រូវចងក្រងឡើង ត្រូវកំណត់ឱ្យបានច្បាស់ ពីអាយុរបស់យុវវ័យ និង ប្រភេទក្រុមគោលដៅ (យុវវ័យងាយរងគ្រោះ ឬ យុវវ័យទូទៅ) ។
- ត្រូវសិក្សាឱ្យបានស៊ីជម្រៅ ទៅបញ្ហា និង តម្រូវការជាក់លាក់របស់យុវវ័យ ជាពិសេសយុវវ័យងាយរងគ្រោះ ដោយសារជំងឺអេដស៍ ដើម្បីកំណត់នូវយុទ្ធសាស្ត្រ និង បទអន្តរាគមន៍ ។
- ក្រុមការងារត្រូវពិនិត្យឯកសារនានា ដែលពាក់ព័ន្ធនានា ដើម្បីប្រមូលពត៌មាន ឱ្យបានទូលំទូលាយ ។
- រៀបចំកិច្ចប្រជុំពិភាក្សា ត្រូវឱ្យមានការចូលរួម ពីតំណាងថ្នាក់ខេត្ត និង ថ្នាក់សហគមន៍ ។

**ជំហាន ឬការងារបន្ទាប់:**

1. បង្កើតក្រុមការងារស្នូល ឬ លេខាធិការដ្ឋាន ដើម្បីដឹកនាំ និង សម្របសម្រួល ក្នុងដំណើរការចងក្រងឯកសារ ។
2. ក្រុមការងារស្នូល ឬ លេខាធិការដ្ឋាននឹងដើរតួនាទីក្នុងការពិនិត្យលើឯកសារ ឬ ព័ត៌មាននានា ដែលជាផ្នែកមួយនៃការដាក់បញ្ចូលក្នុងឯកសារចងក្រង ។
3. រៀបចំបង្កើតនូវបទពិពណ៌នាការងារ (Term of Reference) សម្រាប់ក្រុមការងារ ។

4. រៀបចំកិច្ចប្រជុំ ជាបន្តបន្ទាប់ ដើម្បីពិភាក្សាលើសេចក្តីព្រៀង លើឯកសារដែលបានចងក្រង ។

បានឃើញ និង ឯកភាព អ្នកធ្វើរបាយការណ៍

**ឯ.ឧ ខេដ្ឋ. តែខ គន្ធី** ផង់ ចន្ថន